# សិទ្ធិរបស់អ្នក

## ក្នុងនាមជាជនរងគ្រោះនៃការកេងប្រវ័ញ្ចន៍ ឬការរំលោភបំពានផ្លូវភេទ ដែលប្រព្រឹត្តដោយមន្ត្រី ឬបុគ្គលិកពាក់ព័ន្ធនឹងអង្គការសហប្រជាជាតិ

អ្នកមានសិទ្ធិស្នើសុំជំនួយ និងការគាំទ្រពីអង្គការសហប្រជាជាតិ ប្រសិនបើអ្នកជាជនរងគ្រោះនៃការកេងប្រវ័ញ្ចន៍ ឬការរំលោភបំពានផ្លូវភេទដែលប្រព្រឹត្តដោយមន្ត្រី ឬបុគ្គលិកពាក់ព័ន្ធណាម្នាក់របស់អង្គការសហប្រជាជាតិ។

អ្នកក្លាយជាជនរងគ្រោះនៃការរំលោភបំពានផ្លូវភេទ ប្រសិនបើអ្នកចូលរួមក្នុងសកម្មភាពផ្លូវភេទ ដោយសារតែអ្នកទទួលរងការគំរាមកំហែង ឬត្រូវបានគេបង្ខំឱ្យធ្វើសកម្មភាពនេះ ឬយល់ព្រមចូលរួមក្នុងសកម្មភាពផ្លូវភេទក្រោមលក្ខខណ្ឌមិនស្មើភាពគ្នា ឧទាហរណ៍ ដោយសារតែអ្នកមិនអាចធ្វើការសម្រេចចិត្តដោយសេរី ឬភ័យខ្លាចទទួលរងផលវិបាក ដោយសារតែអ្នកបដិសេធមិនចូលរួមប្រព្រឹត្តអំពើនេះជាដើម។ ក្រោមវិធានរបស់អង្គការសហប្រជាជាតិ អ្នកជាជនរងគ្រោះនៃការរំលោភបំពាន ប្រសិនបើអ្នកចូលរួម ឬក្លាយជាកម្មវត្ថុនៃសកម្មភាពផ្លូវភេទ នៅពេលដែលអ្នកមានអាយុក្រោម ១៨ ឆ្នាំ។ អ្នកជាជនរងគ្រោះដោយសារការរំលោភបំពានផ្លូវភេទផងដែរ ប្រសិនបើមានការប៉ុនប៉ងប្រព្រឹត្តនូវទង្វើណាមួយខាងលើនេះមកលើរូបអ្នក។

អ្នកក្លាយជាជនរងគ្រោះនៃការកេងប្រវ័ញ្ចន៍ផ្លូវភេទ ប្រសិនបើមានគេសន្យាចំពោះអ្នក ឬផ្តល់ឱ្យអ្នកនូវប្រាក់កាស ស្បៀងអាហារ ឬអត្ថប្រយោជន៍ដទៃទៀត ដូចជាលំនៅដ្ឋាន ឬការងារជាថ្នូរនឹងការចូលរួមក្នុងសកម្មភាពផ្លូវភេទជាមួយមន្ត្រី ឬបុគ្គលិកពាក់ព័ន្ធរបស់អង្គការសហប្រជាជាតិ។

ប្រសិនបើអ្នកទទួលរងការកេងប្រវ័ញ្ចន៍ ឬការរំលោភបំពានផ្លូវភេទ អង្គការសហប្រជាជាតិនឹងជួយឱ្យអ្នកទទួលបានសេវាថែទាំវេជ្ជសាស្ត្រ ឬជំនួយផ្សេងទៀតដែលអ្នកប្រហែលជាត្រូវការ ឬចង់បាន។ អង្គការសហប្រជាជាតិក៏ជួយអ្នកស្វែងរកដំណោះស្រាយតាមផ្លូវច្បាប់ដែលមានផងដែរ ប្រសិនបើអ្នកចង់ទទួលបានដំណោះស្រាយតាមផ្លូវច្បាប់។

ការកេងប្រវ័ញ្ចន៍ និងការរំលោភបំពានផ្លូវភេទ ត្រូវបានហាមប្រាម ចំពោះមន្ត្រី និងបុគ្គលិកពាក់ព័ន្ធទាំងអស់របស់អង្គការសហប្រជាជាតិ។ ទង្វើទាំងនេះគឺជាទង្វើដែលមិនអាចទទួលយកបាន ទោះជាក្នុងកាលៈទេសៈណាក៏ដោយ។ អង្គការសហប្រជាជាតិនឹងបញ្ជូនបណ្តឹងស្តីពីការកេងប្រវ័ញ្ចន៍ ឬការរំលោភបំពានផ្លូវភេទ ដើម្បីធ្វើការស៊ើបអង្កេត។ អង្គការសហប្រជាជាតិនឹងខិតខំឱ្យអស់ពីលទ្ធភាព ដើម្បីឱ្យអ្នកដែលប្រព្រឹត្តអំពើទាំងនេះទទួលខុសត្រូវចំពោះទង្វើរបស់ខ្លួន។ នេះរួមមានការដាក់វិធានការវិន័យផ្ទៃក្នុង ឬការសហការជាមួយរដ្ឋជាសមាជិកជាដើម។

ឯកសារនេះរៀបរាប់ពីសិទ្ធិរបស់អ្នក និងរបៀបដែលអង្គការសហប្រជាជាតិនឹងជួយដល់អ្នក។

***គោលការណ៍ណែនាំរបស់អង្គការសហប្រជាជាតិៈ***

សិទ្ធិ តម្រូវការ និងសុវត្ថិភាព និងសេចក្ដីថ្លៃថ្នូររបស់អ្នក គឺអាទិភាព។

អ្នកមានសិទ្ធិមិនទទួលការវិនិច្ឆ័យ ការបន្ទោស ឬការទាមទារឱ្យអ្នកទទួលខុសត្រូវចំពោះគ្រោះថ្នាក់ដែលអ្នកទទួលរងពីការកេងប្រវ័ញ្ចន៍ ឬការរំលោភបំពានផ្លូវភេទ។

អ្នកនឹងទទួលបានជំនួយ សម្រាប់គាំពារសុខមាលភាពរបស់អ្នក និងទទួលបានការគាំទ្រ ដើម្បីឱ្យអ្នកបានធូរស្បើយមកវិញពីហេតុការណ៍ទាំងនេះ។

អ្នកនឹងទទួលរងការរើសអើងដោយសារតែពូជសាសន៍ ជាតិពន្ធុ សញ្ជាតិ វណ្ណៈ សាសនា ជំនឿ ភេទ ភាសា និន្នាការភេទ អត្តសញ្ញាណយេនឌ័រ អាយុ ស្ថានភាពសុខភាព ស្ថានភាពពិការភាព ស្ថានភាពនៃការរស់នៅ ឬហេតុផលដទៃទៀតនោះឡើយ។

***សិទ្ធិរបស់អ្នកក្នុងនាមជាជនរងគ្រោះនៃការកេងប្រវ័ញ្ចន៍ ឬការរំលោភបំពានផ្លូវភេទៈ***

**១. សិទ្ធិទទួលបានការគោរព**

ក. អ្នកនឹងទទួលបានការប្រតិបត្តិ ប្រកបដោយការគួរសម សន្តានចិត្ត វិជ្ជាជីវៈ និងយុត្តិធម៌។

ខ. វប្បធម៌ គុណតម្លៃ និងទស្សនៈរបស់អ្នក នឹងទទួលបានការគោរព។ តម្រូវការរបស់អ្នក និងជម្រើសរបស់អ្នកផ្អែកលើព័ត៌មានដែលបានទទួល នឹងត្រូវចាត់ទុកថាជាអាទិភាពដ៏សំខាន់។

**២. សិទ្ធិក្នុងការទទួលបានជំនួយ និងការគាំទ្រនានា**

ក. អ្នកមានសិទ្ធិទទួលបានជំនួយ និងការគាំទ្រ ស្របតាមតម្រូវការខ្លួនរបស់អ្នក។

ខ. ការទទួលបានជំនួយ ឬការគាំទ្ររបស់អ្នក មិនអាស្រ័យលើថាតើអ្នកបានសហការជាមួយនឹងដំណើរការស៊ើបអង្កេត ឬដំណើរការគណនេយ្យភាព ឬរបៀបដែលអ្នកសហការជាមួយនឹងដំណើរការទាំងនេះនោះឡើយ។

គ. ប្រសិនបើអ្នកត្រូវការ និងចង់បានជំនួយ និងការគាំទ្រ អង្គការសហប្រជាជាតិនឹងជួយអ្នកក្នុងការស្វែងរក និងទទួលបាននៅជំនួយបន្ទាន់ ដូច ជាការថែទាំសុខភាព រាប់បញ្ចូលទាំងសុខភាពផ្លូវភេទ និងបន្តពូជ, ការគាំទ្រផ្លូវចិត្ត, ជំនួយសម្រាប់ការរស់នៅ និងសម្ភារៈជាមូលដ្ឋាន ដូចជាស្បៀង សម្លៀកបំពាក់ មធ្យោបាយធ្វើដំណើរ និងជម្រកសុវត្ថិភាពជាដើម។

ឃ. ប្រសិនបើអ្នកត្រូវការ និងចង់បាន អង្គការសហប្រជាជាតិនឹងជួយអ្នកក្នុងការស្វែងរក និងទទួលបានជំនួយរយៈពេលវែង ដូចជា ការថែទាំសុខភាពគ្រប់ជ្រុងជ្រោយ ការគាំទ្រផ្លូវចិត្ត ការទទួលបានជំនួយផ្លូវច្បាប់ ការគាំទ្រសម្រាប់ជីវភាព ការបណ្ដុះបណ្ដាលជំនាញជាដើម។

ង. សម្រាប់ការគាំទ្រផ្លូវចិត្ត និងស្របតាមបំណងប្រាថ្នារបស់អ្នក ព្រមទាំងឧត្តមប្រយោជន៍របស់អ្នក អ្នកមានសិទ្ធិទទួលបានការអមដំណើរ ដោយមនុស្សម្នាក់ដែលអ្នកជឿទុកចិត្ត នៅពេលដែលអ្នកជ្រើសរើស ឬទៅទទួលជំនួយ និងការគាំទ្រនានា។

ច. ប្រសិនបើអ្នកអាយុក្រោម ១៨ ឆ្នាំ ជំនួយ ឬសេវាទាំងឡាយដែលផ្តល់ឱ្យអ្នក ត្រូវពិចារណាពីអាយុ និងតម្រូវការផ្ទាល់ខ្លួនរបស់អ្នក ឧទាហរណ៍ ការធ្វើសមាហរណកម្មទៅក្នុងសាលារៀនឡើងវិញជាដើម។

ឆ. អ្នកមានសិទ្ធិបដិសេធមិនទទួលយកជំនួយ ឬការគាំទ្រក្នុងទម្រង់ណាមួយនៅពេលណាក៏បានបើទោះជាអ្នកបានចាប់ផ្តើមទទួលជំនួយ ឬការគាំទ្រនេះក៏ដោយ។ ការសម្រេចចិត្តបែបនេះនឹងមិនធ្វើឱ្យអ្នកមិនអាចស្នើសុំ ឬទទួលបានជំនួយ ឬការគាំទ្រនៅដំណាក់កាលក្រោយទៀតនោះឡើយ។

## ៣. សិទ្ធិទទួលបានយុត្តិធម៌ និងគណនេយ្យភាព

ក. អ្នកមានសិទ្ធិដាក់ពាក្យបណ្តឹងអំពីការកេងប្រវ័ញ្ចន៍ ឬការរំលោភបំពានផ្លូវភេទ ដែលប្រព្រឹត្តិដោយមន្ត្រី ឬបុគ្គលិកពាក់ព័ន្ធរបស់អង្គការសហប្រជាជាតិ ទៅកាន់អង្គការសហប្រជាជាតិដែលទទួលខុសត្រូវបញ្ជូនបណ្តឹងរបស់អ្នកឱ្យគេធ្វើការស៊ើបអង្កេត។

ខ. អ្នកមានសិទ្ធិស្វែងរកយុត្តិធម៌ និងគណនេយ្យភាពចំពោះគ្រោះថ្នាក់ដែលអ្នកបានទទួលរង តាមរយៈដំណើរការព្រហ្មទណ្ឌ និងដំណើរការរដ្ឋប្បវេណី ក៏ដូចជាយន្តការរដ្ឋបាល យន្តការដាក់វិន័យ និងយន្តការក្រៅប្រព័ន្ធតុលាការដែលអ្នកអាចរកបាន។

គ. ប្រសិនបើអ្នកចង់បាន អង្គការសហប្រជាជាតិនឹងជួយអ្នកក្នុងការទទួលបានព័ត៌មានអំពីរបៀបទទួលជំនួយផ្លូវច្បាប់ និងវិធីសាស្ត្រល្អបំផុត ដើម្បីស្វែងរកយុត្តិធម៌ និងគណនេយ្យភាព ដូចជាតាមរយៈនីតិវិធីនៅក្នុងប្រទេសជាដើម។

ឃ. ប្រសិនបើអ្នកមានកូនកើតចេញពីការកេងប្រវ័ញ្ចន៍ ឬការរំលោភបំពានផ្លូវភេទ អង្គការសហប្រជាជាតិនឹងខិតខំជួយអ្នករកព័ត៌មាន និងជំនួយផ្លូវច្បាប់ ដើម្បីកំណត់ពីឪពុករបស់កូននេះ និងធ្វើការទាមទារដែលពាក់ព័ន្ធ ប្រសិនបើអ្នកមានបំណងជ្រើសរើសយកជម្រើសមួយនេះ។

## ៤. សិទ្ធិធ្វើការសម្រេចចិត្តពីរបៀបចូលរួមក្នុងដំណើរការរបស់អង្គការសហប្រជាជាតិ

ក. អ្នកមានសិទ្ធិធ្វើការសម្រេចចិត្តថាតើត្រូវចូលរួម ឬសហការក្នុងដំណើរការ ឬនីតិវិធីណាមួយរបស់អង្គការសហប្រជាជាតិ ដូចជាដំណើរការ និងនីតិវិធី ដែលត្រូវបានរៀបចំឡើងដោយសារតែអ្នកជាជនរងគ្រោះនៃករណីកេងប្រវ័ញ្ចន៍ ឬរំលោភបំពានផ្លូវភេទ។

ខ. ប្រសិនបើអ្នកសម្រេចចិត្តមិនចូលរួម ឬសហការនាពេលណាមួយ ជម្រើសនេះនឹងមិនប៉ះពាល់ដល់លទ្ធផលនៃការស៊ើបអង្កេត រួមនឹងការទាមទារឱ្យជនដែលប្រព្រឹត្តមានគណនេយ្យភាពចំពោះអំពើរបស់ខ្លួនឡើយ

។

## ៥. សិទ្ធិទទួលបានព័ត៌មាន

ក. អ្នកមានសិទ្ធិទទួលបានព័ត៌មានឱ្យបានឆាប់បំផុតតាមដែលអាចធ្វើទៅបាន អំពីដំណើរការ និងនីតិវិធីនានា ដែលពាក់ព័ន្ធនឹងការរាយការណ៍ពីករណីកេងប្រវ័ញ្ចន៍ ឬរំលោភបំពានផ្លូវភេទ។

ខ. អ្នកមានសិទ្ធិទទួលព័ត៌មានអំពីគ្រប់សេវាកម្មទាំងអស់ដែលមាន ដើម្បីជួយដល់អ្នក។ ប្រសិនបើអ្នកមានកូន ដែលកើតចេញពីករណីកេងប្រវ័ញ្ចន៍ ឬរំលោភបំពានផ្លូវភេទនេះ អ្នកមានសិទ្ធិទទួលព័ត៌មានអំពីរបៀបកំណត់ដឹងពីអ្នកដែលជាឪពុកកូននេះ ការទាមទារអាហារកិច្ចសម្រាប់កូន និងសិទ្ធិដទៃទៀតសម្រាប់កូនរបស់អ្នក។

គ. អ្នកមានសិទ្ធិទទួលបានព័ត៌មានអំពីស្ថានភាពនៃដំណើរការស៊ើបអង្កេត និងនីតិវិធីផ្សេងទៀត អ្នកមានសិទ្ធិទទួលបានព័ត៌មានអំពីតួនាទី និងជម្រើសដែលអ្នកមាន ដើម្បីចូលរួមក្នុងការស៊ើបអង្កេត និងនៅក្នុងនីតិវិធីផ្សេងៗទៀត។ អង្គការសហប្រជាជាតិនឹងជួយអ្នកទទួលបានព័ត៌មាននេះ និងយល់ពីព័ត៌មាននេះឱ្យបានពេញលេញ។

ឃ. អ្នកមានសិទ្ធិស្នើសុំឱ្យមានការផ្តល់ព័ត៌មានជាភាសាដែលអ្នកអាចយល់បាន និងតាមរបៀបដែលមានភាពច្បាស់លាស់ និងដែលអ្នកងាយស្រួលយល់ ដោយធ្វើការពិចារណាពីកាលៈទេសៈផ្ទាល់ខ្លួនរបស់អ្នក ដូចជាពីការភាពភ្នែក ការស្តាប់ ឬសតិបញ្ញាជាដើម។ ប្រសិនបើអ្នកអាយុក្រោម ១៨ អ្នកមានសិទ្ធិទទួលបានព័ត៌មាន តាមរបៀបដែលមានការពិចារណាពីអាយុរបស់។

## ៦. សិទ្ធិនិយាយឱ្យគេឮ

ក. អ្នកមានសិទ្ធិបញ្ចេញទស្សនៈរបស់អ្នកលើបញ្ហាណាមួយដែលទាក់ទងនឹងសិទ្ធិទាំងនេះ ហើយត្រូវបានស្តាប់ និងឮ។ អ្នកមានសិទ្ធិតស៊ូមតិក្នុងនាមតំណាងឱ្យខ្លួនឯងផ្ទាល់ និងកំណត់តម្រូវការរបស់អ្នក។ អ្វីដែលអ្នកត្រូវនិយាយនឹងត្រូវយកទៅធ្វើការពិចារណា ក្នុងការសម្រេចចិត្ត ឬការចាត់វិធានការនានារបស់អង្គការសហប្រជាជាតិ ដែលអាចប៉ះពាល់ដល់សុវត្ថិភាព សេចក្តីថ្លៃថ្នូរ ឬសុខមាលភាពរបស់អ្នក ឬរបស់មនុស្សដែលជិតស្និទ្ធនឹងអ្នក។

ខ. ពាក់ព័ន្ធនឹងការគាំទ្រផ្លូវចិត្ត និងការគាំទ្រជាក់ស្តែងដល់អ្នក និងស្របតាមបំណងប្រាថ្នា និងឧត្តមប្រយោជន៍របស់អ្នក អ្នកមានសិទ្ធិទទួលបានការអមដំណើរដោយបុគ្គលម្នាក់ ដែលអ្នកទុកចិត្តនៅក្នុងដំណើរការស៊ើបអង្កេត ការសម្ភាស និងកិច្ចប្រជុំនានា។ នៅក្នុងកាលៈទេសៈមួយចំនួន អ្នកអាចទទួលបានការអមដំណើរដោយតំណាងតាមផ្លូវច្បាប់ណាម្នាក់។

គ. អ្នកមានសិទ្ធិលើកឡើងពីតម្រូវការ និងកាលៈទេសៈផ្ទាល់ខ្លួនរបស់អ្នក ដែលអាចប៉ះពាល់ដល់លទ្ធភាពរបស់អ្នកក្នុងការប្រើប្រាស់សិទ្ធិរបស់អ្នកប្រកបដោយប្រសិទ្ធភាព ដើម្បីឱ្យគេស្តាប់ឮ និងយកទៅធ្វើការពិចារណា។ ប្រសិនបើអ្នកអាយុក្រោម ១៨ ឆ្នាំ អ្នកមានសិទ្ធិសុំឱ្យគេរៀបចំនីតិវិធីស៊ើបអង្កេតការសម្ភាស

ឬកិច្ចប្រជុំតាមបែបផែនណា ដែលមានការពិចារណាពីអាយុរបស់អ្នក។ អ្នកមានសិទ្ធិជ្រើសរើសមនុស្សណាម្នាក់ដែលអ្នកជឿទុកចិត្តឱ្យអមដំណើរអ្នក ក្នុងអំឡុងការអនុវត្តនីតិវិធីការសម្ភាស ឬកិច្ចប្រជុំខាងលើ។

ឃ. អ្នកមានសិទ្ធិបង្កើត ឬចងក្រងជាសមាគមជាមួយជនរងគ្រោះដទៃទៀត ប្រសិនបើអ្នកមានបំណងចង់ធ្វើបែបនេះ។

## ៧. សិទ្ធិទទួលបានភាពឯកជន និងការរក្សាការសម្ងាត់

ក. អ្នកមានសិទ្ធិសម្រេចចិត្តពីព័ត៌មានដែលអ្នកត្រូវផ្តល់អំពីស្ថានភាពរបស់អ្នកទៅកាន់អង្គការសហប្រជាជាតិ។ អ្នកអាចមិនចង់ផ្តល់ព័ត៌មានអ្វីក៏បាន ឬអ្នកចង់លែងផ្តល់ព័ត៌មានទៀតក៏បាន ដែលនេះអាចមានឥទ្ធិពល ឬផលប៉ះពាល់លើវិសាលភាព និង/ឬលទ្ធផលនៃការស៊ើបអង្កេត។

ខ. អ្នកមានសិទ្ធិទទួលបានការរក្សាការសម្ងាត់ បើទោះជាអ្នកផ្តល់ព័ត៌មានទៅកាន់បុគ្គលិកអង្គការសហប្រជាជាតិដែលអាចឱ្យគេកំណត់ដឹងពីអត្តសញ្ញាណរបស់អ្នក ព័ត៌មាននេះអាចបញ្ជូនទៅឱ្យបុគ្គលក្នុងក្របខ័ណ្ឌអង្គការសហប្រជាជាតិ ដែលមានភាពចាំបាច់ ក្នុងការដឹងពីព័ត៌មាននេះ ដើម្បីធានាឱ្យជនដែលប្រព្រឹត្តមានការទទួលខុសត្រូវ។ អ្នកមានសិទ្ធិស្នើសុំមិនឱ្យគេបញ្ចេញព័ត៌មានដែលអាចសម្គាល់ដឹងពីអត្តសញ្ញាណរបស់អ្នកទៅក្រៅអង្គការសហប្រជាជាតិ។

គ. អ្នកមានសិទ្ធិដឹងពីគោលបំណងនៃការប្រើប្រាស់ព័ត៌មាននានាដែលអ្នកសម្រេចចិត្តថានឹងផ្តល់ឱ្យ ដូចជាតើព័ត៌មាននេះអាចត្រូវបានលាតត្រដាងទៅបុគ្គលណាខ្លះជាដើម។ អ្នកគួរទទួលបានព័ត៌មានអំពីជម្រើសនានា ដើម្បីរក្សាព័ត៌មាននេះជាការសម្ងាត់ ដែលអាចដាក់កំហិតលើវិសាលភាពនៃការស៊ើបអង្កេត រួមទាំងលទ្ធភាពទាមទារការទទួលខុសត្រូវពីអ្នកប្រព្រឹត្ត។ ការសម្រេចចិត្តរបស់អ្នកក្នុងការមិនផ្តល់ព័ត៌មាន និងមិនប៉ះពាល់ដល់សិទ្ធិរបស់អ្នកក្នុងការទទួលបានជំនួយ និងការគាំទ្រឡើយ។

ឃ. អ្នកមានសិទ្ធិទទួលបានព័ត៌មានពីអង្គការសហប្រជាជាតិអំពីការវាយតម្លៃដែលអង្គការសហប្រជាជាតិធ្វើឡើងលើផលប៉ះពាល់ដែលពាក្យបណ្តឹងរបស់អ្នកអាចមានមកលើសុវត្ថិភាពរបស់អ្នក និងលើសុវត្ថិភាពមនុស្សដែលនៅជិតអ្នក។

## ៨. សិទ្ធិទទួលបានការការពារ

ក. ការរក្សាសុវត្ថិភាពមានសារៈសំខាន់បំផុតចំពោះអង្គការសហប្រជាជាតិ។ ការបៀតបៀន ការគំរាមកំហែង និងការតបតសងសឹកដោយសារតែអ្នកបានរាយការណ៍ពីអ្វីដែលបានកើតឡើងចំពោះអ្នក អ្វីដែលអ្នកឬមនុស្សដែលនៅកៀកនឹងអ្នកបានជួបប្រទះ ឬសាក្សីណាមួយតំណាងឱ្យអ្នក សុទ្ធតែជាទង្វើដែលមិនអាចទទួលយកបាន។ ប្រសិនបើអ្នករាយការណ៍ពីទង្វើទាំងនេះទៅកាន់អង្គការសហប្រជាជាតិ អង្គការសហប្រជាជាតិនឹងចាត់វិធានការ ដើម្បីការពារសុវត្ថិរាងកាយរបស់អ្នក និងការការពារអ្នកពីការប៉ះទង្គិចផ្លូវចិត្ត ឬការរងគ្រោះបន្ថែមទៀត

ស្របតាមបំណងប្រាថ្នារបស់អ្នក តាមរយៈការសហការជាមួយអាជ្ញាធររដ្ឋ ឬអង្គការមិនមែនរដ្ឋាភិបាល។

ខ. អង្គការសហប្រជាជាតិនឹងធ្វើអ្វីៗគ្រប់បែបយ៉ាង ដើម្បីការពារអ្នកពីការជួបទំនាក់ទំនងជាមួយជនដែលត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្តអំពើទាំងនេះ ក្នុងអំឡុងដំណើរការ ឬនីតិវិធីនានាដែលអនុវត្តដោយអង្គការសហប្រជាជាតិ។

គ. អង្គការសហប្រជាជាតិនឹងសហការជាមួយរដ្ឋជាសមាជិក ដើម្បីធានាឱ្យមានការអនុវត្តវិធានការការពារបែបនេះនៅក្នុងនីតិវិធីនានាដែលអនុវត្តនៅក្នុងប្រទេស។

## ៩. សិទ្ធិទទួលបានដំណោះស្រាយ

ក. ជនដែលប្រព្រឹត្តត្រូវទទួលខុសត្រូវរៀងៗខ្លួនចំពោះទង្វើកេងប្រវ័ញ្ចន៍ និងរំលោភបំពានផ្លូវភេទ។ អ្នកមានសិទ្ធិស្នើសុំដំណោះស្រាយពីបុគ្គលទាំងនេះ ដោយមានការទទួលស្គាល់ពីគ្រោះថ្នាក់ដែលអ្នកបានទទួលរង និងស្នើសុំជំនួយ ដើម្បីប៉ះប៉ូវការខូចខាតទាំងនេះ។ ដំណោះស្រាយដែលអ្នកមានសិទ្ធិទទួលបាន គឺអាស្រ័យតាមច្បាប់នៃប្រទេសដែលជាមូលដ្ឋានសម្រាប់ធ្វើការស៊ើបអង្កេត ឬបើកសវនការលើករណីរបស់អ្នក និងអាចមានជាការផ្តល់សំណងផ្នែកហិរញ្ញវត្ថុ ការស្តារលទ្ធភាពពលកម្មកាយសម្បទា និងផ្លូវចិត្ត និងការគាំទ្រផ្នែកសម្ភារៈ ការសុំទោស ឬវិធានការ ដើម្បីធានាមិនឱ្យមានការប្រព្រឹត្តអំពើបែបនេះសារជាថ្មី។

ខ. ប្រសិនបើមានការកំណត់ដឹងឪពុករបស់កូនដែលកើតឡើងដោយសារការកេងប្រវញ្ចន៍ ឬការរំលោភបំពានផ្លូវភេទ អ្នកមានសិទ្ធិសុំឱ្យមានការអនុវត្តនីតិវិធីចំពោះបុរសជាឪពុកនេះ ដើម្បីទាមទារឱ្យគាត់ទទួលខុសត្រូវក្នុងនាមជាមេបារបស់កូននេះ រួមទាំងការតម្រូវឱ្យបុគ្គលនេះផ្តល់ការគាំទ្រអាហារកិច្ចដល់កុមារស្របតាមច្បាប់ជាតិ ដែលមានជាធរមានៅក្នុងប្រទេសដែលធ្វើការកាត់សេចក្តីលើករណីរបស់អ្នក។ កូនរបស់អ្នកអាចទាមទារសិទ្ធិបន្ថែមទៀត ដូចជាសិទ្ធិសញ្ជាតិ ឬពលរដ្ឋរបស់ឪពុកជាដើម។ អង្គការសហប្រជាជាតិនឹងជួយអ្នកក្នុងដំណើរការទាំងនេះ ក៏ដូចជាសហការជាមួយរដ្ឋពាក់ព័ន្ធ ដើម្បីសម្របសម្រួលឱ្យមានការឆ្លើយតបចំពោះការទាមទារទាំងនេះប្រកបដោយភាពត្រឹមត្រូវ និងយុត្តិធម៌។

## ១០. សិទ្ធិដាក់ពាក្យបណ្តឹងលើការប្រតិបត្តិដែលអ្នកបានទទួល

ក. ប្រសិនបើអ្នកគិតថាសិទ្ធិនៅក្នុងឯកសារនេះ មិនត្រូវបានអង្គការសហប្រជាជាតិគោរព អ្នកមានសិទ្ធិប្តឹងទៅការិយាល័យអ្នកគាំទ្រសិទ្ធិជនរងគ្រោះ។ បណ្តឹងរបស់អ្នកនឹងត្រូវបានពិចារណា ហើយនឹងទទួលបានព័ត៌មានអំពីស្ថានភាពនៃវិធានការនានា ដែលអនុវត្តជាការឆ្លើយតបស្របតាមបំណងប្រាថ្នារបស់អ្នក។

ខ. អ្នកនឹងទទួលបានការការពារពីការតបតសងសឹកនានាពីអង្គការសហប្រជាជាតិ ប្រសិនបើអ្នកដាក់ពាក្យបណ្តឹងនេះ។

សូមទាក់ទងទៅកាន់ការិយាល័យអ្នកគាំទ្រសិទ្ធិជនរងគ្រោះ តាមរយៈអ៊ីមែល៖ ovra@un.org.